**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៧៨...អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការកាត់ដីទំហំ ១.៧៣១ ហិកតា នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សំរាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋសរុប ២២០ គ្រួសារ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.សក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៦៤ ខបជ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ១.៧៣១ ហិកតា ចេញពីតម្រប់ព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សំរាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប ២២០ គ្រួសារ នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ២២០ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយ-មានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។



www.pheakdeylaw.com

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*



www.pheakdeylaw.com

**ឧបសម្ព័ន្ធ នៃ. អនុក្រឹត្យលេខ...៣៨...អនក្រ.បក ចុះថ្ងៃទី ១៥....ខែ...កុម្ភៈ.....ឆ្នាំ ២០១៣**
**ស្តីពីការកាត់ដីទំហំ ១.៧៣១ ហិកតា នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ចេញពីគម្របព្រៃឈើឆ្នាំ ២០០២**
**និងធ្វើ អនុបយោគជាដីឯកជនរបស់រដ្ឋ សំរាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋសរុប ២២០ គ្រួសារ**




| ចំណុចនិយាមកា | | | | | |
|---|---|---|---|---|---|
| UTM Zone 48N Datum WGS84 | | | | | |
| Code | X_Coor | Y_Coor | Code | X_Coor | Y_Coor |
| 1 | 260294 | 1536520 | 42 | 262989 | 1533377 |
| 2 | 260341 | 1536826 | 43 | 262952 | 1533250 |
| 3 | 260339 | 1537154 | 44 | 262849 | 1533222 |
| 4 | 260365 | 1537330 | 45 | 262581 | 1533233 |
| 5 | 261369 | 1537328 | 46 | 262342 | 1533340 |
| 6 | 263378 | 1537320 | 47 | 261867 | 1533139 |
| 7 | 263384 | 1537222 | 48 | 261806 | 1533080 |
| 8 | 263369 | 1537118 | 49 | 261388 | 1533108 |
| 9 | 263372 | 1536823 | 50 | 261346 | 1533049 |
| 10 | 263600 | 1536843 | 51 | 261222 | 1532985 |
| 11 | 263884 | 1536845 | 52 | 261098 | 1533061 |
| 12 | 264339 | 1536801 | 53 | 261032 | 1533103 |
| 13 | 264411 | 1536518 | 54 | 260892 | 1533263 |
| 14 | 264467 | 1536436 | 55 | 260631 | 1533334 |
| 15 | 264804 | 1536108 | 56 | 260580 | 1533359 |
| 16 | 265335 | 1535510 | 57 | 260541 | 1533729 |
| 17 | 265237 | 1535162 | 58 | 260579 | 1533876 |
| 18 | 265164 | 1535048 | 59 | 260518 | 1534053 |
| 19 | 265086 | 1534879 | 60 | 260405 | 1534156 |
| 20 | 265051 | 1534618 | 61 | 260349 | 1534260 |
| 21 | 265137 | 1534621 | 62 | 260309 | 1534623 |
| 22 | 265184 | 1534794 | 63 | 260208 | 1534924 |
| 23 | 265367 | 1534782 | 64 | 260346 | 1534942 |
| 24 | 265359 | 1534582 | 65 | 260293 | 1535019 |
| 25 | 265352 | 1534437 | 66 | 260281 | 1535047 |
| 26 | 265349 | 1534400 | 67 | 260269 | 1535085 |
| 27 | 265320 | 1534300 | 68 | 260242 | 1535186 |
| 28 | 265304 | 1534176 | 69 | 260238 | 1535302 |
| 29 | 265234 | 1533817 | 70 | 260256 | 1535432 |
| 30 | 264908 | 1533759 | 71 | 260282 | 1535506 |
| 31 | 264776 | 1533767 | 72 | 260364 | 1535561 |
| 32 | 264730 | 1533613 | 73 | 260409 | 1535557 |
| 33 | 264677 | 1533595 | 74 | 260389 | 1535667 |
| 34 | 264510 | 1533584 | 75 | 260680 | 1535803 |
| 35 | 264355 | 1533625 | 76 | 260851 | 1535910 |
| 36 | 264207 | 1533706 | 77 | 260896 | 1535954 |
| 37 | 263906 | 1533532 | 78 | 261019 | 1536205 |
| 38 | 263824 | 1533589 | 79 | 260856 | 1536274 |
| 39 | 263443 | 1533400 | 80 | 260866 | 1536327 |
| 40 | 263327 | 1533402 | 81 | 260771 | 1536388 |
| 41 | 263254 | 1533375 | 82 | 260821 | 1536518 |

**តំណាងសំគាល់**

- ចំណុចគោល លេខ 1 ដល់ លេខ 82
- ចំណុចលំអិតមាននៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់
- ព្រំប្រទល់ដីកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ 1731 ha ជូនប្រជាពលរដ្ឋចំនួន 220 គ្រួសារ

**ចាប់នីយាមដោយឧបករណ៍**

GARMIN GPSmap 62s (UTM ZONE 48N Datum WGS 1984)